**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងបំពេញបន្ថែមអនុប្រធាន និងសមាជិកក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល



www.pheakdeylaw.com

## សម្រេច

**ប្រការ១.**

ត្រូវបានតែងតាំងបំពេញបន្ថែមអនុប្រធាន និង សមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅរាជធានី ខេត្ត ដូចខាងក្រោម៖

១-ខេត្តប៉ៃលិន ៖

| | | |
|---|---|---|
| ១- ឯកឧត្តម វ៉ង សុធី | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ២-លោកជំទាវ គោ ពិឡា | ទីប្រឹក្សាសម្តេចក្រឡាហោម ស ខេង | អនុប្រធាន |

២-ខេត្តបាត់ដំបង៖

| | | |
|---|---|---|
| ១- ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ស៊ីនួន | នាយរងសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ | សមាជិក |
| ២- លោក ហាវ វិសិដ្ឋ | អនុប្រធានរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

៣-ខេត្តស្វាយរៀង៖

| | | |
|---|---|---|
| ១-ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉ក់ សារុន | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ | សមាជិក |
| ២-ឯកឧត្តម ចាប សុថារិទ្ធ | នាយកខុទ្ទកាល័យ លោកជំទាវឧបនាយករដ្ឋមន្ត្រីម៉ែន សំអន | សមាជិក |
| ៣-លោកជំទាវ ពៅ ដានី | ទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៤-លោក ប៊ូ បូរិន | អគ្គនាយករងអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |

៤-ខេត្តបន្ទាយមានជ័យ៖

| | | |
|---|---|---|
| ១-ឯកឧត្តម គោ ស៊ុំសារឿត | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២-លោក បាន បុត្តា | អគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងសុខាភិបាល | សមាជិក |

៥-រាជធានីភ្នំពេញ៖

| | | |
|---|---|---|
| ១-លោកស្រី ទេព រ៉ូដា | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |



www.pheakdeylaw.com

៦-ខេត្តកំពង់ស្ពឺ៖

១-លោក ង៉ូវ បូរីណា — អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច — សមាជិក

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តប៉ៃលិន រដ្ឋបាលខេត្តបាត់ដំបង រដ្ឋបាលខេត្តស្វាយរៀង រដ្ឋបាលខេត្តបន្ទាយមានជ័យ រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២.ខែ កក្កដា ឆ្នាំ២០១៦

តប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

សម្តេចក្រឡាហោម ស ខេង

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com